**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ០៣៧ ដនស/សជណ.

ថ្ងៃពុធ ១ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពីការប្រឡងប្រជែងជ្រើសរើស និស្សិត និងមន្ត្រីរាជការទូទៅឱ្យចូលបម្រើការងារ ក្នុងក្របខណ្ឌក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់ឆ្នាំ ២០២០

**យោង** : លិខិតលេខ ៥៣៥៦ មស.ក្រឧ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៩ របស់ក្រសួងមុខងារសាធារណៈ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមជូនដំណឹងដល់និស្សិត និងមន្ត្រីរាជការទូទៅដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅឱ្យបានជ្រាបថា ក្រសួងនឹងរៀបចំការប្រឡងប្រជែងជ្រើសរើសនិស្សិត និងមន្ត្រីរាជការទូទៅឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រភេទក្របខណ្ឌ "ក" ចំនួន ៤៤ កន្លែង។ និស្សិត និងមន្ត្រីរាជការទូទៅដែលមានជំនាញដូចខាងក្រោមអាចដាក់ពាក្យសុំប្រឡងប្រជែងបាន ហើយជនពិការនិងជនជាតិដើមភាគតិចត្រូវបានលើកទឹកចិត្ត និងផ្តល់អាទិភាព÷

**ក. ទីស្តីការក្រសួង ជ្រើសរើសចំនួន ០៦ កន្លែង ÷**

- ជំនាញវិស្វកម្មសំណង់ស៊ីវិល ចំនួន ០២ កន្លែង
- ជំនាញស្ថាបត្យកម្ម ចំនួន ០២ កន្លែង
- ជំនាញធរណីមាត្រ ចំនួន ០២ កន្លែង

**ខ. មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ជ្រើសរើសចំនួន ៣៨ កន្លែង ÷**

**១. មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តព្រះសីហនុ ចំនួន ១៥ កន្លែង**
- ជំនាញវិស្វកម្មសំណង់ស៊ីវិល ចំនួន ០៥ កន្លែង
- ជំនាញស្ថាបត្យកម្ម ចំនួន ០៥ កន្លែង
- ជំនាញធរណីមាត្រ ចំនួន ០៥ កន្លែង

**២. មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តបាត់ដំបង ចំនួន ០៣ កន្លែង**
- ជំនាញវិស្វកម្មសំណង់ស៊ីវិល ចំនួន ០១ កន្លែង
- ជំនាញស្ថាបត្យកម្ម ចំនួន ០១ កន្លែង
- ជំនាញធរណីមាត្រ ចំនួន ០១ កន្លែង

**៣. មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តសៀមរាប ចំនួន ០៥ កន្លែង**
- ជំនាញវិស្វកម្មសំណង់ស៊ីវិល ចំនួន ០២ កន្លែង
- ជំនាញស្ថាបត្យកម្ម ចំនួន ០២ កន្លែង
- ជំនាញធរណីមាត្រ ចំនួន ០១ កន្លែង

**៤. មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តស្វាយរៀង ចំនួន ០៣ កន្លែង**
- ជំនាញវិស្វកម្មសំណង់ស៊ីវិល ចំនួន ០១ កន្លែង
- ជំនាញស្ថាបត្យកម្ម ចំនួន ០១ កន្លែង
- ជំនាញធរណីមាត្រ ចំនួន ០១ កន្លែង

**៥.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តបន្ទាយមានជ័យ ចំនួន ០៣ កន្លែង**

- ជំនាញវិស្វកម្មសំណង់ស៊ីវិល ចំនួន ០១ កន្លែង
- ជំនាញស្ថាបត្យកម្ម ចំនួន ០១ កន្លែង
- ជំនាញរេខាគណិត ចំនួន ០១ កន្លែង

**៦.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្ដាល ចំនួន ០៣ កន្លែង**

- ជំនាញវិស្វកម្មសំណង់ស៊ីវិល ចំនួន ០១ កន្លែង
- ជំនាញស្ថាបត្យកម្ម ចំនួន ០១ កន្លែង
- ជំនាញរេខាគណិត ចំនួន ០១ កន្លែង

**៧.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកែប ចំនួន ០២ កន្លែង**

- ជំនាញវិស្វកម្មសំណង់ស៊ីវិល ចំនួន ០១ កន្លែង
- ជំនាញស្ថាបត្យកម្ម ចំនួន ០១ កន្លែង

**៨.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត ចំនួន ០២ កន្លែង**

- ជំនាញវិស្វកម្មសំណង់ស៊ីវិល ចំនួន ០១ កន្លែង
- ជំនាញស្ថាបត្យកម្ម ចំនួន ០១ កន្លែង

**៩.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ស្ពឺ ចំនួន ០២ កន្លែង**

- ជំនាញវិស្វកម្មសំណង់ស៊ីវិល ចំនួន ០១ កន្លែង
- ជំនាញស្ថាបត្យកម្ម ចំនួន ០១ កន្លែង

## គ. លក្ខខណ្ឌនៃការជ្រើសរើស ÷

បេក្ខជន និងបេក្ខនារី ត្រូវ ÷

- មានសញ្ជាតិខ្មែរ
- មានអាយុមិនលើសពី ៣៥ ឆ្នាំ ករណីមានសញ្ញាបត្របរិញ្ញាបត្រ
- មានអាយុមិនលើសពី ៤០ ឆ្នាំ ករណីមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់
- បានលើកលែងលក្ខខណ្ឌអាយុ ចំពោះបេក្ខជនជាមន្ត្រីរាជការទូទៅ និងបេក្ខជនជានិស្សិតដែលមានសញ្ញាបត្រថ្នាក់បណ្ឌិតឡើងទៅ
- មានលិខិតអនុញ្ញាតពីប្រធានស្ថាប័ន ចំពោះបេក្ខជនជាមន្ត្រីរាជការទូទៅ
- បានលើកទឹកចិត្តនិងផ្តល់អាទិភាពចំពោះបេក្ខជនជានិស្សិត និងជាមន្ត្រីរាជការទូទៅដែលមានអាសយដ្ឋានបច្ចុប្បន្ននៅតាមខេត្តគោលដៅ
- បានផ្តល់អាទិភាពនិងលើកទឹកចិត្តចំពោះបេក្ខជនជាមន្ត្រីរាជការទូទៅ និងនិស្សិតដែលជាជនជាតិដើមភាគតិច និងជនពិការដែលអាចបំពេញការងារបាន
- បម្រើការងារនៅតាមខេត្តគោលដៅខាងលើរយៈពេល ០៥ ឆ្នាំយ៉ាងតិចនៅពេលប្រឡងជាប់ ។

## ឃ. កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យសុំប្រឡង ÷

និស្សិត និងមន្ត្រីរាជការទូទៅដែលមានបំណងប្រឡងប្រជែងចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវដាក់ពាក្យសុំចុះឈ្មោះប្រឡងនៅទីស្តីការក្រសួងដែលមានអាសយដ្ឋានលេខ៧៧១-៧៧៣ មហាវិថីព្រះមុន្នីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ **(នាយកដ្ឋានបុគ្គលិកជាន់ទី២ បន្ទប់ ២១៨)** រយៈពេល **៣០ថ្ងៃ ជាការប្រញាប់ ចាប់ពីថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៩ រហូតដល់ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០១៩** រៀងរាល់ម៉ោងធ្វើការ ។

**ខ. សំណុំលិខិតសុំចុះឈ្មោះប្រឡងមាន ៖**

| | |
|---|---|
| ១. ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ ច្បាប់ |
| ២. ជីវប្រវត្តិសង្ខេបមានបិទរូបថតថ្មី ៤x៦ | ចំនួន ០១ ច្បាប់ |
| ៣. កិច្ចសន្យាបម្រើការងារ | ចំនួន ០១ ច្បាប់ |
| ៤. សលាកបត្រឯកត្តជន មានបិទរូបថតថ្មី ៤x៦ | ចំនួន ០១ ច្បាប់ |
| ៥. បង្កាន់ដៃទទួលពាក្យសុំសិទ្ធិប្រឡង | ចំនួន ០១ ច្បាប់ |
| ៦. សេចក្តីចម្លងសញ្ញាបត្រទុតិយភូមិ ឬសញ្ញាបត្រសមមូល ដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ | ចំនួន ០១ ច្បាប់ |
| ៧. សេចក្តីចម្លងសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ | ចំនួន ០១ ច្បាប់ |
| ៨. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ | ចំនួន ០១ ច្បាប់ |
| ៩. ច្បាប់ចម្លងបណ្ណគ្រួសារ ឬ សៀវភៅស្នាក់នៅ ដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ | ចំនួន ០១ ច្បាប់ |
| ១០. សេចក្តីចម្លងសំបុត្រកំណើត ឬសាលក្រម | ចំនួន ០១ ច្បាប់ |
| ១១. លិខិតថ្កោលទោស (ពេលប្រឡងជាប់) | ចំនួន ០១ ច្បាប់ |

**ច. កាលបរិច្ឆេទ និងមណ្ឌលប្រឡង ៖**

**១.កាលបរិច្ឆេទ** ៖ ថ្ងៃសៅរ៍ ទី ២៨ ខែធ្នូ ឆ្នាំ ២០១៩ វេលាម៉ោង ៧ : ០០ នាទីព្រឹក

**២.មណ្ឌលប្រឡង** ៖ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (រាជធានីភ្នំពេញ)

**៣.មុខវិជ្ជាប្រឡង** ៖ **១.** ចំណេះដឹងទូទៅ **រយៈពេល ១ម៉ោង៣០នាទី**

**២.** ជំនាញ **រយៈពេល ២ម៉ោង**

និស្សិត និងមន្ត្រីរាជការទូទៅអាចមកទទួលយកពាក្យស្នើសុំប្រឡងប្រជែងដោយឥតគិតថ្លៃនៅនាយកដ្ឋានបុគ្គលិក ជាន់ទី២ បន្ទប់លេខ ២១៨ ឬអាចទាញយកពាក្យស្នើសុំប្រឡងប្រជែងតាមអាសយដ្ឋានគេហទំព័រ www.mlmupc.gov.kh និង Facebook Page របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំពោះព័ត៌មានលម្អិតផ្សេងៗទៀត និស្សិត និងមន្ត្រីរាជការទូទៅ អាចមកសាកសួរនៅនាយកដ្ឋានបុគ្គលិក ជាន់ទី២ បន្ទប់លេខ ២១៨ នៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រៀងរាល់ម៉ោងធ្វើការ ។

❖ *កំណត់សម្គាល់ : សេចក្តីជូនដំណឹងនេះត្រូវចាត់ទុកជាការប្រញាប់។*

**ឋ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ និងជាប្រធានគណៈកម្មការប្រឡង**

**ឆាន់_សាផាន**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ជួយផ្សព្វផ្សាយ)
- ឯកសារ - កាលប្បវត្តិ